ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ២១៧៦ ឧក.ឧ.កគសជល

ថ្ងៃ ពុធ ១០កើត ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានកិត្តិយសជម្រាបជូនសាធារណជន រូបវន្តបុគ្គល/នីតិបុគ្គល ទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានសហការជាមួយកម្មវិធីការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) ដែលទទួលជំនួយឥតសំណងពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈ DFAT ក្នុងគោលបំណងធ្វើការសិក្សាឃុំមួយចំនួនដែលពុំទាន់ មានទឹកស្អាតប្រើប្រាស់ ដើម្បីរៀបចំឯកសារដាក់ដេញថ្លៃជាសាធារណៈ ក្នុងការជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅឃុំទាំងនោះ។

ក្រសួងសូមប្រកាសជូនដំណឹងដាក់ដេញថ្លៃជាសាធារណៈ ជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅ ឃុំគោកបល្ល័ង្គ (៨ភូមិ/៨ភូមិ) និងសំបួរ (១១ភូមិ/១១ភូមិ) ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដែលមានលក្ខខណ្ឌ ដូចខាងក្រោមនេះ ៖

1. ទុនវិនិយោគសរុប៖ ៥១១ ៩៧០ ដុល្លារអាមេរិក សម្រាប់អនុវត្តគម្រោងរយៈពេល ៥ឆ្នាំ
2. អ្នកចូលរួមត្រូវមាន៖ ទុនវិនិយោគយ៉ាងតិច ៣៥% នៃទុនវិនិយោគសរុប
3. ប្រាក់កក់ធានាចូលរួមដេញថ្លៃ ៖ ៥ ០០០ដុល្លារអាមេរិក (មានលិខិតបញ្ជាក់ពីធនាគារ)
4. ថវិកាឧបត្ថម្ភពីគម្រោង (3i) ៖ ២០៧ ២០៦ ដុល្លារអាមេរិក (ឧបត្ថម្ភតាមលទ្ធផលនៃជំហាននីមួយៗ)
5. ថ្លៃលក់ទឹក (ដេញថ្លៃ) ៖- ពី០ម៣ ទៅដល់ ៣ម៣ ថ្លៃលក់ ២០០០៛/ម៣
   - ចាប់ពី ៤ម៣ឡើងទៅថ្លៃលក់ ចន្លោះពី ២ ១០០៛/ម៣ដល់ ២ ៤០០៛/ម៣
6. ព័ត៌មានលម្អិតមានក្នុងឯកសារដេញថ្លៃ ដែលអាចរកជាបានឯកសារនៅនាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបន្ទាយមានជ័យ។ លោកអ្នកក៏អាចស្វែងរកព័ត៌មានសង្ខេបថ្មីសំខាន់ៗ ក្នុងគេហទំព័រ៖ www.3icambodia.org
7. កិច្ចប្រជុំណែនាំស្តីពីការរៀបចំឯកសារចូលរួមដេញថ្លៃនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០១៨ វេលាម៉ោង០៩: ០០ នាទីព្រឹក នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបន្ទាយមានជ័យ។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៨ វេលាម៉ោង ០៩: ០០ នាទីព្រឹក នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបន្ទាយមានជ័យ ជាកំហិត។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ឯក សុនចាន់


- នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
  លោក សៀង យុត្តិរ៉ា 092 768 699
  អ៊ីម៉ែល៖ yuthera@gmail.com
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបន្ទាយមានជ័យ
  លោក ញឹល ប៊ុនធឿន 089 446 003, 097 720 2028
- កម្មវិធីការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) 012 819 105
  អ៊ីមែល៖ info@3icambodia.org